សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខៈ ៦៧
ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខៈ ៣៩៩
ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០
សាលក្រមលេខៈ ៨១ "ជ"
ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បានថតចម្លងត្រឹមត្រូវចេញពីច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប, ថ្ងៃទី១២ ខែ[illegible] ឆ្នាំ២០២០
ក្រឡាបញ្ជី

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តសៀមរាប សាលសវនាការ[redacted]
កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ៨:៣០នាទីព្រឹក
កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ៣:៣០នាទីរសៀល

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៦៧ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **ភារ៉ា** ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ សាសនា ព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃុំខ្លួននៅភូមិ[redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៩ មុខរបរ លក់មាន់ ឪពុកឈ្មោះ [redacted] ឆាយ "រ" ម្ដាយឈ្មោះ [redacted] គា "រ" ប្រពន្ធឈ្មោះ [redacted] ស៊ីដែង "រ" មានកូនចំនួន ០២នាក់ ប្រវត្តិផ្ដន្ទាទោសដោយតុលាការ គ្មាន (ក្នុងឃុំ)។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ។

២-ឈ្មោះ [redacted] **សសមុទ្រ** ហៅ **ជានូទ១៦០** ភេទប្រុស កើតឆ្នាំ១៩៨៦ ជាតិខ្មែរ សាសនា ព្រះពុទ្ធ ទីកន្លែងកំណើតនៅភូ[redacted] រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] សំអុល "រ" ម្ដាយឈ្មោះ [redacted] សូជិន "រ" ប្រពន្ធឈ្មោះ [redacted] សុជាតិ (គេចខ្លួន)។

មានលោក[redacted] ជាមេធាវីការពារសិទ្ធិ។

ត្រូវជាប់ចោទពីបទៈ**ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មល់ចែក ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ ,៥ ចំណុច ៦ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ឈ្មោះ [redacted] សុខ ភេទប្រុស កើតឆ្នាំ២០០១ ជាតិខ្មែរ សាសនា ព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅមិនពេលចាប់ខ្លួន នៅភូមិដំដែកផ្សារ ឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៨ មុខរបរ គ្មាន ឪពុកឈ្មោះ [redacted] រួត "រ" ម្តាយឈ្មោះ [redacted] នួន "រ" ប្រវត្តិផ្តន្ទាទោសដោយតុលាការគ្មាន នៅលីវ (ក្នុងឃុំ)។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ។

៤-ឈ្មោះ [redacted] រ៉ាយូ ភេទប្រុស កើតឆ្នាំ១៩៨៧ ជាតិខ្មែរ សាសនា ព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិគោកមន ឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ប៉ែន "រ" ម្តាយឈ្មោះ [redacted] តាំងអ៊ិន "រ" នៅលីវ (គេចខ្លួន)។

ត្រូវជាប់ចោទពីបទ៖ **សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្នល់ចែក ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ កថាខណ្ឌ ៣ ,៥ ចំណុច ៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៣០៥ អ.យ/២០ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ១៩០០/២០២០ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខៈ ៥៧៦ ពស.ព្រជ (ក) ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

-បានឃើញ ដីកាផ្តល់ដំណឹងកាលបរិច្ឆេទសវនាការ ដែលធ្វើឡើងដោយមានអនុលោមតាមមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ដំណើររឿងហេតុកើតឡើងមានដូចតទៅ

កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១២និង៣០នាទី កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀនសហការណ៍ជាមួយអធិការដ្ឋាននគរបាលស្រុកសូទ្រនិគម បានចុះបង្ក្រាបករណីគ្រឿងញៀន នៅចំណុចហាងអ៊ុតសក់ ស្ថិតនៅភូមិថ្នល់ចែក ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប ឃាត់ខ្លួនបានមនុស្សម្នាក់ឈ្មោះ [redacted] ការ៉ា ដកហូតបានថ្នាំញៀនចំនួន ២២កញ្ចប់ ទម្ងន់ ៦៧,៩ក្រាម ព្រមទាំងឧបករណ៍ប្រើប្រាស់វេចខ្ចប់មួយចំនួនទៀត ដែលជនសង្ស័យកំពុងតែវេចខ្ចប់។ ក្រោយពីសួរនាំឈ្មោះ [redacted] ការ៉ា បានសារភាពថាបានទិញថ្នាំញៀនពីឈ្មោះ [redacted] សសមុទ្រ ហើយក៏ធ្លាប់ប្រើឲ្យឈ្មោះ [redacted] សុរី ទៅយកថ្នាំញៀនចំនួន ០៤លើក និងឈ្មោះ [redacted] រ៉ាយូ ទៅយកបានចំនួន ០២លើក។ ក្រោយមកនៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០២០ សមត្ថកិច្ចបានចាប់ខ្លួនឈ្មោះ [redacted] សុរី តាមដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ។



Scanned with CamScanner

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ភារ៉ា បានឆ្លើយថា៖ ខ្លួនទទួលស្គាល់បទចោទប្រកាន់ និងអង្គហេតុដែលតុលាការបានអានឲ្យស្តាប់។ កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ០៩:៣០នាទីព្រឹក ពេលដែលខ្លួនកំពុងនៅក្នុងរោងកាត់សក់របស់បងថ្លៃឈ្មោះ [redacted]ជា នៅភូមិថ្នល់ចែក ឃុំថ្នល់ចែក ស្រុកសូទ្រនិគម ខេត្តសៀមរាប ឈ្មោះ វី បានយកគ្រឿងញៀនប្រភេទម៉ាទឹកកក មកខ្ចីកន្លែងខ្លួនដើម្បីវែលកកូនថង់តូចៗ ពេលនោះខ្លួនកំពុងតែអង្គុយមើលនៅទីនោះដែរ។ បន្ទាប់ពីឈ្មោះ វី បានវែលកថ្នាំញៀនរួចរាល់ហើយ នោះឈ្មោះ វី ក៏បានចេញទៅក្រៅដោយប្រាប់ថាទៅតែមួយភ្លាពទេដោយទុកគ្រឿងញៀននៅក្នុងបន្ទប់នោះដែរ។ មួយសន្ទុះក្រោយមកស្រាប់តែសមត្ថកិច្ចក៏ចូលមកដល់ភ្លាមតែម្តងចាប់ឃាត់ខ្លួនព្រមទាំងវត្ថុតាងតែម្តង។ ខ្លួនធ្លាប់មានទំនាក់ទំនងជាមួយឈ្មោះ វី តាមរយៈទូរស័ព្ទដោយយកក្នុងម្តងៗតម្លៃ ១០ដុល្លារ យកមកប្រើប្រាស់ខ្លួនឯង។ ខ្លួនធ្លាប់យកពីឈ្មោះ វី បានចំនួន ០២លើកមកហើយ។ ខ្លួនស្គាល់ឈ្មោះ វ៉ាយូ គឺជាអ្នកយកថ្នាំញៀនមកឲ្យឈ្មោះ វី រួចក៏បានយកមកខ្ចីកន្លែងខ្លួនដើម្បីបំបែកថ្នាំ។ ខ្លួនមិនបានជួយវែលកគ្រឿងញៀនជាមួយឈ្មោះ វី ទេ គ្រឿងញៀននោះមាន ២២កញ្ចប់តូច (១៧កញ្ចប់ធំ និង ៥កញ្ចប់តូច)។ ខ្លួនធ្លាប់ទិញគ្រឿងញៀនពីឈ្មោះ សាយ ដោយទិញម្តង ១,៥០០,០០០រ (មួយលានហាសិបម៉ឺនរៀល) ទិញបានពីរដងហើយ។ ចំពោះឈ្មោះ [redacted] សសមុទ្រ ខ្លួនមិនធ្លាប់ស្គាល់ទេក៏មិនធ្លាប់ទិញពីឈ្មោះនេះដែរ។ នៅស្នងការប៉ូលីសខ្លួនធ្លាប់ឆ្លើយថាស្គាល់ឈ្មោះ សាយ (១៦១) មិនមែនឈ្មោះ [redacted] សសមុទ្រ ទេ។ ឈ្មោះ វី នោះរស់នៅស្រុកប្រាសាទបាគង ឪពុកឈ្មោះ ឃ្លោក ម្តាយឈ្មោះ នួន។ ឈ្មោះ វ៉ាយូ ខ្លួនមិនដែលប្រើឲ្យវាយកគ្រឿងញៀនឲ្យគេទេ។ ខ្លួនទើបស្គាល់ឈ្មោះ វី នោះបានប្រហែល ១០ថ្ងៃប៉ុណ្ណោះ ដោយឲ្យឈ្មោះនេះយកគ្រឿងញៀនឲ្យគេបានចំនួន ០២លើក ខ្លួនមិនស្គាល់ឈ្មោះ វី រស់នៅទីណាទេ។ ខ្លួនមានអ្នកលក់បន្តឲ្យខ្លួនឈ្មោះ សេង និងឈ្មោះ ហុក។ ចំពោះឈ្មោះ [redacted] ស៊ុវី ដែលត្រូវគេចាប់មកនេះខ្លួនមិនស្គាល់ទេឈ្មោះ វី ដែលខ្លួនបានឆ្លើយថា ធ្លាប់យកគ្រឿងញៀនឲ្យខ្លួននោះ គឺមានអាយុច្រើនជាងខ្លួន និងមានមាឌធំ មិនមែនឈ្មោះ [redacted] ស៊ុវី ដែលគេចាប់មកទេ។ ខ្លួនមិនធ្លាប់ទិញគ្រឿងញៀនពីអ្នកណាក្រៅពីឈ្មោះ សាយ ទេ ដោយខ្លួនស្គាល់តាមរយៈលេខទូរសព្ទ័។ ចំពោះចម្លើយរបស់ខ្លួនឆ្លើយនៅប៉ូលីសទាក់ទងនឹងឈ្មោះ វី នោះ គឺពិតប្រាកដមែន ប៉ុន្តែចំពោះឈ្មោះ វី ដែលបង្ហាញមុខនៅតុលាការនេះ គឺមិនមែនវាទេ។ ខ្លួនមិនដែលមានទំនាក់ទំនងអ្វីជាមួយឈ្មោះ វី ដែលគេចាប់ខ្លួនមកនេះទេ។ នៅក្នុងរូបថតដែលតុលាការបង្ហាញនោះ គឺឈ្មោះ សាយ ហៅ ១៦១ ហើយរូបនោះហើយដែលជាអ្នកលក់គ្រឿងញៀនឲ្យខ្លួន។ ខ្លួនធ្លាប់ទិញគ្រឿងញៀនយកមកប្រើប្រាស់ និងលក់បន្តឲ្យគេបានចំនួន ០២លើក។ មូលហេតុដែលខ្លួនចេះលក់បន្ត ព្រោះឈ្មោះ សាយ ណែនាំឲ្យខ្លួនលក់បន្ត។ មកដល់ពេលនេះខ្លួនដឹងកំហុសហើយ និងភ្ញាក់រលឹកឈប់ប្រព្រឹត្តអំពើខុសហើយ។ ខ្លួនសូមបញ្ជាក់ថាឈ្មោះ វី ដែលត្រូវគេចាប់មកនេះមកមែនជាអ្នកយកគ្រឿងញៀនឲ្យគេបន្តនោះទេឈ្មោះ វី នោះ គឺរស់នៅភូមិថ្មី។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] សុខ បានឆ្លើយថា៖ ខ្លួនមិនស្គាល់អ្នកឈរក្រោយខ្លួននោះទេ។ ខ្លួនមិនដែលស្គាល់ឈ្មោះ ភារ៉ា ទេ។ ម្ដាយខ្លួនឈ្មោះ នួន រស់នៅភូមិដំដែកផ្សារ (ធ្លាប់ធ្វើការនៅប្រទេសថៃ) ឪពុកខ្លួនឈ្មោះ ឈ្លោក (ហៅក្រៅ)។ ខ្លួនឈប់ប្រើប្រាស់គ្រឿងញៀនបានពីរបីខែហើយ ដោយប្រើប្រាស់ចុងក្រោយនៅខែមករា ឆ្នាំ២០២០ ខ្លួនមិនធ្លាប់យកគ្រឿងញៀនឲ្យអ្នកណាទេ គ្រឿងញៀនដែលខ្លួនយកមកប្រើប្រាស់នោះ គឺទិញពីអ្នកមិនស្គាល់តាមរយៈលេខទូរសព្ទ័មិនចាំ ដោយគ្រឿងញៀនត្រូវគេប្លុងចោលនៅភូមិថ្នល់ដាច់។ ចំពោះរូបដែលតុលាការបង្ហាញនោះខ្លួនមិនស្គាល់ទេ។ ខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] ភារ៉ា ទេ។ ក្នុងពេលសវនាការលើកមុនខ្លួនពិតជាធ្លាប់ឆ្លើយថា ធ្លាប់ដេកជាមួយឈ្មោះ [redacted] ភារ៉ា និងធ្លាប់យកគ្រឿងញៀនឲ្យគេជំនួសឈ្មោះ [redacted] មែន ដោយឈ្មោះ ភារ៉ា នេះឲ្យខ្លួនសម្រាប់មួយជក់ៗប៉ុណ្ណោះ។ ខ្លួនធ្លាប់ប្រើប្រាស់គ្រឿងញៀនបានតែពីរដងប៉ុណ្ណោះ មិនធ្លាប់លក់គ្រឿងញៀនឲ្យអ្នកណាដែរ។ ខ្លួនមិនធ្លាប់ស្គាល់ឈ្មោះ [redacted] ភារ៉ា ទេ ចំពោះការចោទប្រកាន់ថាខ្លួន យកគ្រឿងញៀនឲ្យគេជំនួសឈ្មោះ [redacted] ភារ៉ា នោះ គឺមិនពិតទេ។

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា ជនជាប់ចោទឈ្មោះ [redacted] ភារ៉ា ពិតជាបានធ្វើសកម្មភាពទិញ និងលក់គ្រឿងញៀនឲ្យគេប្រាកដមែន ចំពោះគ្រឿងញៀន គឺមានដល់ទៅ ២២កញ្ចប់ ទម្ងន់ ៦៩ក្រាម ហើយជននេះមានជំនាញខ្លាំងណាស់ក្នុងការជួញដូរគ្រឿងញៀន ហើយជននេះសកម្មណាស់ក្នុងការចែកចាយគ្រឿងញៀនបន្ត តំណាងអយ្យការស្នើសុំផ្ដន្ទាទោសជននេះក្នុងកម្រិតអតិបរមា ដោយឡែកចំពោះជនជាប់ចោទឈ្មោះ [redacted] សសមុទ្រ ជាអ្នកលក់គ្រឿងញៀនបន្តឲ្យឈ្មោះ [redacted] ភារ៉ា ដែលមានរឿងក្ដីជាច្រើននៅតុលាការ ហើយជននេះជាជនដែលបង្កគ្រោះថ្នាក់ខ្លាំងណាស់នៅក្នុងសង្គម ហេតុនេះតំណាងអយ្យការស្នើសុំផ្ដន្ទាទោសជននេះក្នុងកម្រិតអតិបរមា និងពិចារណាដល់ករណីមិនរៀងចាលផងដែរ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] ស៊ុវី គឺមិនព្រមសហការជាមួយតុលាការដើម្បីស្វែងរកការពិតនោះទេ បើជាឆ្លើយភូតកហុកបង្វែងដានពីអង្គហេតុទៅវិញ ហេតុនេះតំណាងអយ្យការស្នើសុំតុលាការផ្ដន្ទាទោសជននេះក្នុងនាមសហចារីតែម្ដង និងក្នុងកម្រិតអតិបរមាផងដែរ ចំពោះជនជាប់ចោទឈ្មោះ [redacted] វ៉ាយុ ស្នើសុំរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ: ៣០៥ អ.យ/២០ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាបទុកជាបានការដដែល និងប្ដឹងសុំឲ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ភារ៉ា និងឈ្មោះ [redacted] ស៊ុវី បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ និងសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការឃើញថា កូនក្ដីខ្លួនឈ្មោះ [redacted] ភារ៉ា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយហេតុថាឈ្មោះ [redacted] ភារ៉ា បានដឹងពីកំហុសរបស់ខ្លួនមិនបានបង្កផលលំបាកក្នុងការស្វែងរកការពិត ហេតុដូច្នេះសូមផ្ដល់ស្ថានសម្រាលដល់កូនក្ដីខ្លួន តាមមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ដល់កូនក្ដីខ្លួន។ ចំពោះឈ្មោះ [redacted] ស៊ុវី គឺគាត់មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ដោយយោងតាមការឆ្លើយរបស់ឈ្មោះ [redacted] ភារ៉ា នាពេលសវនាការផ្ទាល់តែម្ដង ហេតុនេះស្នើសុំតុលាការឲ្យកូនក្ដីខ្លួនឈ្មោះ [redacted] ស៊ុវី បានរួចផុតពីបទចោទប្រកាន់ផងចុះ។



Scanned with CamScanner

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សសមុទ្រ បានធ្វើសេចក្តីសន្និដ្ឋានការពារថា ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ឃើញថាកូនក្តីខ្លួនឈ្មោះ [redacted] សសមុទ្រ គឺមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ យោងតាមការឆ្លើយរបស់ជនជាប់ចោទនាពេលសវនាការ ហេតុដូច្នេះស្នើសុំតុលាការឲ្យកូនក្តីខ្លួនឈ្មោះ [redacted] សសមុទ្រ បានរួចផុតបទចោទប្រកាន់។

<u>សិទ្ធិនិយាយស្តីរបស់ជនជាប់ចោទបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល</u>

-ជនជាប់ចោទឈ្មោះ [redacted] **ភារ៉ា** បានធ្វើការកត់សម្គាល់ថា៖ មានសំណូមពរឲ្យតុលាការបន្ធូរបន្ថយទោសឲ្យខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] **សុខ** បានធ្វើការកត់សម្គាល់ថា៖ មានសំណូមពរឲ្យតុលាការឲ្យខ្លួនបានរួចផុតពីបទចោទប្រកាន់ផងចុះ។

ផ្អែកតាមកិច្ចពិភាក្សាដេញដោល

ក្រោយពីបានស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារដែលបានកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ និងប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានពិនិត្យ ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>យល់ឃើញថា</u>

-តាមរបាយការណ៍សំយោគលេខ ០៧២/២០ ប្រ.គ្រ.ញ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានបញ្ជាក់ថា៖ ឈ្មោះ [redacted] ភារ៉ា និងឈ្មោះ [redacted] សសមុទ្រ ពិតជាបានធ្វើសកម្មភាព ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន រីឯឈ្មោះ [redacted] រ៉ាយូ និងឈ្មោះ [redacted] សុរី ពិតជាបានធ្វើសកម្មភាពសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

-ជនជាប់ចោទឈ្មោះ [redacted] ភារ៉ា បានឆ្លើយសារភាពថា ខ្លួនពិតជាធ្លាប់បានលក់ និងចែកចាយគ្រឿងញៀនឲ្យគេប្រាកដមែន ដោយគ្រឿងញៀនទាំងអស់នោះខ្លួនបានទិញពីឈ្មោះ [redacted] ហៅ ១៦១ ទិញម្តងៗតម្លៃ ១,៥០០,០០០៛ (មួយលានប្រាំសែនរៀល)។ ផ្អែកតាមចម្លើយសារភាពនេះ ឃើញថាជនជាប់ចោទរូបនេះពិតជាបានធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។

-ជនជាប់ចោទឈ្មោះ [redacted] ភារ៉ា បានឆ្លើយដោះសារឲ្យបក្ខពួករបស់ខ្លួនរួមមានឈ្មោះ [redacted] សសមុទ្រ និងឈ្មោះ [redacted] សារី ដោយបានឆ្លើយអះអាងថា ខ្លួនមិនស្គាល់ឈ្មោះ [redacted] សសមុទ្រ ទេកន្លងមក ចំពោះឈ្មោះ [redacted] សារី ដែលត្រូវតុលាការចាប់ខ្លួនមកនេះក៏រូបខ្លួនមិនស្គាល់ដែរប៉ុន្តែបើយោងតាមចម្លើយរបស់ជនជាប់ចោទរូបនេះបានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ,ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ ក៏ដូចជានាពេលសវនាការ គឺបានឆ្លើយយ៉ាងច្បាស់ពីឈ្មោះឪពុកម្តាយ មុខរបរ និងទីលំនៅរបស់ឪពុកម្តាយរបស់

ជនជាប់ចោទឈ្មោះ [redacted] សារី ហើយពេលតុលាការសួរជនជាប់ចោទឈ្មោះ [redacted] សារី គឺឈ្មោះនេះបានឆ្លើយយ៉ាងច្បាស់ដូចគ្នាទៅនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ភារ៉ា។ នេះសបញ្ជាក់ឲ្យឃើញថាឈ្មោះ [redacted] សារី ដែលត្រូវតុលាការចាប់ខ្លួនមកនេះ គឺពិតជាមនុស្សតែមួយនឹងឈ្មោះ [redacted] សារី ដែលត្រូវតុលាការចោទប្រកាន់ពីបទ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

ដោយឡែកចំពោះជនជាប់ចោទឈ្មោះ [redacted] សសមុទ្រ តុលាការបានបង្ហាញរូបថតឲ្យឈ្មោះ [redacted] ភារ៉ា មើលនាពេលសវនាការ ហើយជនជាប់ចោទឈ្មោះ [redacted] ភារ៉ា បានឆ្លើយថារូបនេះហើយដែលជាអ្នកលក់គ្រឿងញៀនឲ្យខ្លួន ប៉ុន្តែឈ្មោះ [redacted] ភារ៉ា បានឆ្លើយដោះសារបង្វែរដានថាមនុស្សក្នុងរូបថតនោះ គឺមានឈ្មោះ សាយ ហៅ ១៦១ ទៅវិញ។ នេះបញ្ជាក់ឲ្យឃើញដូចគ្នាថាឈ្មោះ [redacted] សសមុទ្រ ក៏ជាមេខ្លោងជួញដូរគ្រឿងញៀនមួយរូបដ៏សកម្មផងដែរដោយជននេះហើយដែលជាអ្នកចែកចាយគ្រឿងញៀនបន្តឲ្យឈ្មោះ [redacted] ភារ៉ា។ ហេតុដូចនេះមានន័យថាឈ្មោះ [redacted] សសមុទ្រ ពិតជាបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន។

ចំពោះជនជាប់ចោទឈ្មោះ [redacted] រ៉ាយូ ត្រូវបានជនជាប់ចោទឈ្មោះ [redacted] ភារ៉ា ឆ្លើយសារភាពនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ,ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ ថាខ្លួនធ្លាប់បានប្រើឲ្យឈ្មោះនេះទៅលក់គ្រឿងញៀនឲ្យខ្លួនបានចំនួន ០២លើក។ ហេតុដូចនេះមានន័យថាជនជាប់ចោទឈ្មោះ [redacted] រ៉ាយូ ពិតជាបានប្រព្រឹត្តអំពើ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

-តាមចម្លើយសារភាពរបស់ជនជាប់ចោទ មានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងឯកសារដែលបានកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ដែលបង្ហាញឲ្យឃើញថានៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១២ និង ៣០នាទី កម្លាំងការិយាល័យប្រឆាំងគ្រឿងញៀនសហការណ៍ជាមួយកម្លាំងអធិការដ្ឋាននគរបាលស្រុកសូទ្រនិគម បានចុះបង្ក្រាបមុខសញ្ញាជួញដូរគ្រឿងញៀនឈ្មោះ [redacted] ភារ៉ា នៅចំណុចហាងអ៊ុតសក់ នៅភូមិថ្នល់ចែក ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាបដកហូតបានថ្នាំញៀនម៉ាទឹកកកចំនួន ២២កញ្ចប់ ដែលមានទម្ងន់ ៦៧.៥ក្រាម , ថ្នាំញៀនយ៉ាម៉ាពណ៌ក្រហម ដែលមានប្រភេទគ្រាប់ចំនួន ០៧គ្រាប់ និងប្រភេទម្សៅចំនួន ០១កញ្ចប់ សរុបទម្ងន់ ០,៦ក្រាម ព្រមទាំងឧបករណ៍ប្រើប្រាស់វេចខ្ចប់គ្រឿងញៀនមួយចំនួនដែលវត្ថុតាងទាំងអស់នេះជនសង្ស័យខាងលើបានកំពុងធ្វើសកម្មភាពវែកវេចខ្ចប់នៅក្នុងទីតាំងដែលសមត្ថកិច្ចយើងចុះទៅបង្ក្រាប។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ជនជាប់ចោទឈ្មោះ [redacted] ភារ៉ា ពិតជាបានធ្វើសកម្មភាពទិញ និងលក់គ្រឿងញៀនឲ្យគេប្រាកដមែន ចំពោះគ្រឿងញៀន គឺមានដល់ទៅ ២២កញ្ចប់ ទម្ងន់ ៦៥ក្រាម ហើយជននេះមានជំនាញខ្លាំងណាស់ក្នុងការជួញដូរគ្រឿងញៀនហើយជននេះសកម្មណាស់ក្នុងការចែកចាយគ្រឿងញៀនបន្ត តំណាងអយ្យការស្នើសុំផ្តន្ទាទោសជននេះក្នុងកម្រិតអតិបរមា ដោយឡែកចំពោះជនជាប់ចោទឈ្មោះ [redacted] សសមុទ្រ ជាអ្នក

លក់គ្រឿងញៀនបន្តឲ្យឈ្មោះ [redacted] ភាវ៉ា ដែលមានរឿងក្តីជាច្រើននៅតុលាការ ហើយជននេះជាជនដែលបង្កគ្រោះថ្នាក់ខ្លាំងណាស់នៅក្នុងសង្គម ហេតុនេះតំណាងអយ្យការស្នើសុំផ្តន្ទាទោសជននេះក្នុងកម្រិតអតិបរមា និងពិចារណាដល់ករណីមិនរៀងចាលផងដែរ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] សុរី គឺមិនព្រមសហការជាមួយតុលាការដើម្បីស្វែងរកការពិតនោះទេ បើជាឆ្លើយភូតកហុកបង្វែងដានពីរវង្គហេតុទៅវិញ ហេតុនេះតំណាងអយ្យការស្នើសុំតុលាការផ្តន្ទាទោសជននេះក្នុងនាមសហចារីតែម្តង និងក្នុងកម្រិតអតិបរមាផងដែរ។ ចំពោះជនជាប់ចោទឈ្មោះ ផន វ៉ាយូ ស្នើសុំរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ៣០៥ អ.យ/២០ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាបទុកជាបានការដដែល និងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ គប្បីតុលាការពិនិត្យ និងសម្រេចតាមការស្នើសុំ។

-កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ នៅភូមិថ្នល់ចែក ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប ពិតជាមានអំពើ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បានកើតឡើង ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ភាវ៉ា និងឈ្មោះ [redacted] សសមុទ្រ ប្រាកដមែន។

-កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ នៅភូមិថ្នល់ចែក ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប ពិតជាមានអំពើ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បានកើតឡើង ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] វ៉ាយូ និងឈ្មោះ [redacted] សុរី ប្រាកដមែន។

-អំពើរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ទៅលើសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសន្តិសុខសង្គម និងប៉ះពាល់ដល់ច្បាប់របស់រដ្ឋ។

-ជនជាប់ចោទឈ្មោះ [redacted] ភាវ៉ា និងឈ្មោះ [redacted] សសមុទ្រ មានចេតនាទុច្ចរិតដោយបានធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀនដែលអំពើនេះច្បាប់បានបញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ , ៥ ចំណុច ៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ជនជាប់ចោទឈ្មោះ [redacted] វ៉ាយូ និងឈ្មោះ [redacted] សុរី មានចេតនាទុច្ចរិតដោយបានធ្វើសកម្មភាពសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលអំពើនេះច្បាប់បានបញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌបទ ៖ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលហេនចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ កថាខណ្ឌ ៣ , ៥ ចំណុច ៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តាមកំណត់ហេតុធ្វើតេស្តទឹកនោមរកសារធាតុញៀនលើជនជាប់ចោទឈ្មោះ [redacted] ភាវ៉ា ឃើញថា លទ្ធផលវិជ្ជមានដែលមានភាពស៊ីសង្វាក់គ្នាទៅនឹងចម្លើយរបស់ឈ្មោះ [redacted] ភាវ៉ា ដែលបានឆ្លើយសារភាពថា ពិតជាធ្លាប់បានប្រើប្រាស់នូវថ្នាំញៀន ប្រាកដមែន។

-មិនមានភស្តុតាងណាមួយដែលបញ្ជាក់ថា ជនជាប់ចោទមានបញ្ហាស្មារតី គឺបញ្ជាក់បានថាជនជាប់ចោទមានសតិល្អត្រឹមត្រូវ និងយល់ដឹងបានពីអំពើដែលខ្លួនបានប្រព្រឹត្ត គឺជាបទល្មើសព្រហ្មទណ្ឌ តែជននេះនៅតែប្រព្រឹត្ត។



Scanned with CamScanner

-មានភស្តុតាងដាក់បន្ទុក ធាតុផ្សំបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted] **ភារ៉ា** ភេទប្រុស អាយុ ៣០ឆ្នាំ និងឈ្មោះ [redacted] **សសមុទ្រ** ហៅ **ដានូ១១៦០** ភេទប្រុស កើតឆ្នាំ១៩៨៦ ពីបទ ៖ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិថ្នល់ចែក ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ , ៥ ចំណុច ៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មានភស្តុតាងដាក់បន្ទុក ធាតុផ្សំបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ[redacted] **រ៉ាយូ** ភេទប្រុស កើតឆ្នាំ១៩៨៧ និងឈ្មោះ [redacted] **សុខ** ភេទប្រុស កើតឆ្នាំ២០០១ ពីបទ៖ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិថ្នល់ចែក ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ កថាខណ្ឌ ៣ , ៥ ចំណុច ៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-វត្ថុចាប់យករួមមាន៖ ស្រោមសំបុត្រពណ៌សបិទជិត (គ្រឿងញៀន) មានស្នាមម្រាមដៃឈ្មោះ [redacted] ភារ៉ា និងហត្ថលេខារបស់អ្នកចូលរួមចំនួន ០១ ,ស្រោមសំបុត្រពណ៌ខ្លីមខ្មៅបិទជិត (សម្ភារៈប្រើប្រាស់) មានស្នាមម្រាមដៃឈ្មោះ [redacted] ភារ៉ា និងហត្ថលេខារបស់អ្នកចូលរួមចំនួន ០១ និងទូរស័ព្ទ VIVO មិនស្គាល់ Model មានស៊ីម Cellcard និងMetfone ពណ៌សលាយខៀវ ចំនួន ០១គ្រឿង គប្បីតុលាការសម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ។

## សាលាដំបូង ខេត្តសៀមរាប
## វិនិច្ឆ័យសេចក្តី

I-ផ្តន្ទាទោសជនជាប់ចោទ៖

១-ឈ្មោះ[redacted] **ភារ៉ា** ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ (អត្តសញ្ញាណដូចខាងលើ)

២-ឈ្មោះ [redacted] **សសមុទ្រ** ហៅ **ដានូ១១៦០** ភេទប្រុស កើតឆ្នាំ១៩៨៦ ជាតិខ្មែរ (អត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៨ (**ប្រាំបី**) **ឆ្នាំ** និងពិន័យជាប្រាក់ចំនួន ១០,០០០,០០០៛ (ដប់លានរៀល)។

ពីបទៈ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្នល់ចែក ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ ៣ ,៥ ចំណុច ៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-ឈ្មោះ[redacted] **សុខ** ភេទប្រុស កើតឆ្នាំ២០០១ ជាតិខ្មែរ (អត្តសញ្ញាណដូចខាងលើ)

៤-ឈ្មោះ [redacted] **រ៉ាយូ** ភេទប្រុស កើតឆ្នាំ១៩៨៧ ជាតិខ្មែរ (អត្តសញ្ញាណដូចខាងលើ)ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៥ (**ប្រាំ**) **ឆ្នាំ** និងពិន័យជាប្រាក់ចំនួន ១០,០០០,០០០៛ (ដប់លានរៀល)។



Scanned with CamScanner

ពីបទ: **សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្នល់ចែក ឃុំកៀនសង្កែ ស្រុកសូទ្រនិគម ខេត្តសៀមរាប កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ កថាខណ្ឌ ៣ , ៥ ចំណុច ៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

II-ចេញដីកាបង្គាប់ឲ្យចាប់ខ្លួន៖

១-ឈ្មោះ [redacted] **សសមុទ្រ** ហៅ **ដានូវ១៦០** ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ

២-ឈ្មោះ [redacted] **រ៉ាយុ** ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ

ដើម្បីយកមកអនុវត្តទោសតាម អំណាចសាលក្រមនេះ ស្របតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

III-វត្ថុចាប់យករួមមាន៖

១-ស្រោមសំបុត្រពណ៌សបិទជិត (គ្រឿងញៀន) មានស្នាមម្រាមដៃឈ្មោះ [redacted] ភារ៉ា និងហត្ថលេខារបស់អ្នកចូលរួម ចំនួន ០១។

២-ស្រោមសំបុត្រពណ៌ខ្លីមខ្នុរបិទជិត (សម្ភារៈប្រើប្រាស់)មានស្នាមម្រាមដៃឈ្មោះ [redacted] ភារ៉ា និងហត្ថលេខារបស់អ្នកចូលរួមចំនួន ០១។

៣-ទូរស័ព្ទ VIVO មិនស្គាល់ Model មានស៊ីម Cellcard និង Metfone ពណ៌សលាយខៀវ ចំនួន ០១គ្រឿង។

**ត្រូវសម្រេចរឹបអូស។**

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **ភារ៉ា** ,ឈ្មោះ [redacted] **សុវ** និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **សសមុទ្រ** ហៅ **ដានូវ១៦០** ,ឈ្មោះ [redacted] **រ៉ាយុ**។

ទុកសិទ្ធិទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|

ហត្ថលេខា និងត្រ[redacted]

---

| **បានឃើញ** | **បានចម្លងត្រឹមត្រូវតាមច្បាប់ដើម** |
|---|---|
| ថ្ងៃចន្ទ ៤កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ | ថ្ងៃចន្ទ ៤កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ |
| សៀមរាប ,ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ | សៀមរាប ,ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ |
| **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |